00718588

E96/4

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ បារាំង

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១

**ឯកសារទទួល**
**DOCUMENT RECEIVED/DOCUMENT REÇU**
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 22 / 07 / 2011
ម៉ោង (Time/Heure) : 11:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ / Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សេចក្តីសង្ខេបតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា**
**ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី**

---

ដាក់ដោយ៖

**សហមេធាវីការពារក្តីលោក ខៀវ សំផន**

មេធាវី ស សូវាន

មេធាវី Jacques VERGÈS

**ជំនួយការ៖**

លោកស្រី សេង សុជាតា

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម ធូ មណី

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

E96/4

០០២/១៩-០៩-២០០៧-អវតក/អជសជ

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## I. សេចក្តីផ្តើម

១. យោងតាមសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១[1] សហព្រះរាជអាជ្ញាស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសថា គេមិនមានសិទ្ធិដាច់ខាតណាមួយក្នុងការតម្រូវឱ្យសាក្សីចូលមកបង្ហាញខ្លួនឡើយ ខណៈសក្ខីកម្មរបស់ពួកគេកំពុងតែត្រូវបានស្នើសុំឱ្យដាក់បញ្ចូលជាធាតុនៃភ័ស្តុតាង និងស្នើសុំឱ្យសម្រេចលើភាពចាំបាច់ក្នុងការកោះហៅសាក្សីឱ្យមកបង្ហាញខ្លួនក្នុងសវនាការនៅពេលចាប់ផ្តើមដំណាក់កាលនីមួយៗនៃកិច្ចដំណើរការនីតិវិធី ដោយអនុវត្តតាមគោលការណ៍ណែនាំទូទៅនៃវិធាន ៩២ ស្ទួន នៃវិធាននីតិវិធីនិងភ័ស្តុតាង របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងប្រតិចារឹកនៃសក្ខីកម្មជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់") និង យុត្តិសាស្ត្ររបស់តុលាការនេះ។

២. លោក ខៀវ សំផន សូមធ្វើសេចក្តីសង្កេតតបមួយចំនួន ដើម្បីរំឭកអង្គជំនុំជម្រះថាការកោះហៅសាក្សី គឺជាគោលការណ៍ ហើយការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ត្រូវស្ថិតនៅក្នុងករណីពិសេស និងត្រូវមានការធានាអះអាងយ៉ាងហ្មត់ចត់។

## II. ច្បាប់ជាធរមាន

### ក. វិធាន និងបទប្បញ្ញត្តិច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក

៣. សហព្រះរាជអាជ្ញាយល់ឃើញថា នីតិវិធីអនុវត្តនៅចំពោះមុខ អ.វ.ត.ក មានភាពមិនច្បាស់លាស់ និងមានចន្លោះប្រហោង[2]។ សហព្រះរាជអាជ្ញាលើកឡើងថា "វិធានផ្ទៃក្នុងមិនបានចែងថា តើអង្គ

---

[1] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E96 (សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា)។ សំណៅជាភាសាបារាំងនៃឯកសារនេះ ត្រូវបានជូនដំណឹង នៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១។

[2] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣ ដល់កថាខណ្ឌ ៦។

៨. សហព្រះរាជអាជ្ញាយោងទៅលើសេចក្តីសម្រេចជាច្រើនរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ដោយលើកឡើងថាសិទ្ធិរបស់ជនជាប់ចោទក្នុងការសួរសាក្សីនានា ដែលចម្លើយរបស់ខ្លួនត្រូវបានទទួលយកធ្វើជាភស្តុតាង មិនមែនគ្មានកម្រិតនោះទេ នៅពេលកំណត់ហេតុស្តាប់ចម្លើយសាក្សីត្រូវបានបញ្ជាក់បន្ថែមដោយភស្តុតាងផ្សេងទៀត[6]។

៩. លោក ខៀវ សំផន សូមគូសបញ្ជាក់ថា នៅក្នុងសេចក្តីសម្រេចនីមួយៗ តុលាការសិទ្ធិមនុស្សអឺរ៉ុប រំឭកថា៖

"ជាគោលការណ៍ ភស្តុតាងត្រូវដាក់នៅចំពោះជនជាប់ចោទនៅក្នុងសវនាការជាសាធារណៈ ដើម្បីធ្វើការដេញដោលតទល់គ្នា។ គោលការណ៍នេះមិនមានគ្មានការលើកលែងនោះទេ ប៉ុន្តែ គេនឹងអាចទទួលយកភស្តុតាងតែប្រសិនបើមានការគោរពសិទ្ធិការពារខ្លួន។ កថាខណ្ឌ ១ និងកថាខណ្ឌ ៣(ឃ) នៃមាត្រា ៦ បង្គាប់ជាទូទៅឲ្យផ្តល់ឱកាសសមស្រប និងគ្រប់គ្រាន់ដល់ជនជាប់ចោទក្នុងការជំទាស់ទៅនឹងសក្ខីកម្មដាក់បន្ទុក និងសួរសាក្សី ក្នុងពេលធ្វើសក្ខីកម្ម ឬនៅពេលក្រោយ"[7]។

១០. តុលាការសិទ្ធិមនុស្សអឺរ៉ុបបានកំណត់យ៉ាងច្បាស់ថា សិទ្ធិការពារខ្លួនត្រូវបានរឹតត្បិតក្នុងលក្ខណៈមិនស្របគ្នាទៅនឹងការធានានៃមាត្រា ៦ នៅពេលការផ្តន្ទាទោសផ្អែក តែម៉្យាងគត់ *ឬក្នុងវិធានការកំណត់* ទៅលើសក្ខីកម្មរបស់សាក្សីមួយរូប ដែលជនជាប់ចោទមិនមានលទ្ធភាពក្នុងការសួរ ឬឲ្យមេធាវីសួរ នៅដំណាក់កាលស៊ើបសួរ និងក្នុងសវនាការជជែកដេញដោល[8]។

---

[6] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩ ដល់កថាខណ្ឌ ១១។

[7] ឧទាហរណ៍ សូមមើល៖ តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Rachdad តទល់នឹងប្រទេសបារាំង* សំណុំរឿងលេខ ៧១៨៤៦/០១ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៣ កថាខណ្ឌ ២៣ (មិនមានគូសបន្ទាត់ពីក្រោមនៅក្នុងឯកសារដើម) ; រឿងក្តី *Saïdi តទល់នឹងប្រទេសបារាំង* សំណុំរឿងលេខ ១៤៦៤៧/៨៩ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៤៣ ; រឿងក្តី *Isgro តទល់នឹងប្រទេសអ៊ីតាលី* សំណុំរឿងលេខ ១១៣៣៩/៨៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩១ កថាខណ្ឌ ៣៤។

[8] ឧទាហរណ៍ សូមមើល៖ តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Rachdad តទល់នឹងប្រទេសបារាំង* សំណុំរឿងលេខ ៧១៨៤៦/០១ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៣ កថាខណ្ឌ ២៣ ; រឿងក្តី *Sadak និងអ្នកផ្សេងទៀត តទល់នឹងប្រទេសទួរគី* សំណុំរឿងលេខ ២៩៩០០/៩៦, ២៩៩០១/៩៦, ២៩៩០២/៩៦ និង ២៩៩០៣/៩៦ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១ កថាខណ្ឌ ៦៥ ; រឿងក្តី *A.S.*

ករណីរឿងក្តីធ្ងន់ធ្ងរ រសើប និងស្មុគស្មាញបំផុត ឧទាហរណ៍ អំពើហិង្សាផ្លូវភេទលើអនីតិជន[12] ឬ ការជួញដូរគ្រឿងញៀន[13]។

## គ. តុលាការឧក្រិដ្ឋកម្មអន្តរជាតិ៖ គោលការណ៍ និងការអនុវត្ត

១៤. សហព្រះរាជអាជ្ញាបានបង្ហាញការវិភាគទៅលើវិធាន និងយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី សំដៅបញ្ចុះបញ្ចូលអង្គជំនុំជម្រះឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ជាលក្ខណៈទូទៅ និងប្រកបដោយភាពបត់បែន[14]។

១៥. លោក ខៀវ សំផន សូមរំឭកថា យោងតាមវិធាន និងយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី គោលការណ៍គឺនៅតែជាគោលការណ៍កោះហៅសាក្សីឱ្យចូលក្នុងសវនាការជានិច្ច ហើយច្បាស់ណាស់ ការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ មិនត្រូវធ្វើជាទូទៅនោះទេ ហើយត្រូវគោរពលក្ខខណ្ឌតឹងរ៉ឹង។

---

[12] ឧទាហរណ៍ សូមមើល៖ តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *A.S. តទល់នឹងប្រទេសហ្វាំងឡង់* សំណុំរឿងលេខ ៤០១៥៦/០៧ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ៥៦៖ "ដោយទទួលស្គាល់ភាពចាំបាច់ក្នុងការធានាតុល្យភាពរវាងសិទ្ធិរបស់ចុងចោទ និងសិទ្ធិរបស់កុមារដែលអះអាងថាជាជនរងគ្រោះ តុលាការយល់ឃើញថាត្រូវមានការធានាជាអប្បបរមាដូចតទៅ៖ ជនសង្ស័យត្រូវទទួលបានការជូនដំណឹងអំពីសវនាការស្តាប់ចម្លើយកុមាររងគ្រោះ។ ជនសង្ស័យត្រូវមានលទ្ធភាពតាមដានសវនាការនោះ ទាំងក្នុងពេលកំពុងប្រព្រឹត្តិទៅ ឬនៅពេលក្រោយ តាមរយៈឧបករណ៍សោតទស្សន៍ **និងមានសិទ្ធិសួរកុមាររងគ្រោះនោះ ដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ក្នុងពេលដំណើរការសវនាការដំបូង ឬនៅពេលក្រោយ**" (មិនមានអក្សរដិត ក្នុងឯកសារដើម)។

[13] ឧទាហរណ៍ សូមមើល៖ តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Saïdi តទល់នឹងប្រទេសបារាំង* សំណុំរឿងលេខ ១៤៦៤៧/៨៩ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៣ កថាខណ្ឌ៤៤៖ "តុលាការទទួលស្គាល់ការលំបាកមិនអាចប្រកែកបាន ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរគ្រឿងញៀន ជាពិសេស ក្នុងការស្រាវជ្រាវ និងការគ្រប់គ្រងភស្តុតាង ហើយតុលាការក៏ទទួលស្គាល់ផងដែរនូវការខូចខាតដែលបង្កឡើងដោយការជួញដូរគ្រឿងញៀននៅក្នុងសង្គម ប៉ុន្តែ ការខូចខាតទាំងនេះមិនអាចនាំទៅដល់ការកម្រិតសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទដល់ថ្នាក់នេះទេ"។

[14] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១២ ដល់កថាខណ្ឌ ២៧។

១៨. ភាពខុសគ្នារវាងវិធានទាំងពីរនេះត្រូវបានពន្យល់យ៉ាងច្បាស់ នៅក្នុងសាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី នៅក្នុងរឿងក្តី *Galic*[17] ដែលជា "មូលដ្ឋានសម្រាប់បកស្រាយវិធាន ៩២ស្ទួន នៃវិធាននីតិវិធី និងភស្តុតាង"[18]។ ដូច្នេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើកឡើងថា៖

"យោងតាមវិធាន ៨៩(គ) គេអាចអនុញ្ញាតឱ្យភាគីណាមួយបង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីសក្ខានុពល ដែលបានកត់ត្រាដោយអ្នកស៊ើបអង្កេតរបស់ការិយាល័យរដ្ឋអាជ្ញា ដើម្បីរួចផុតពីភាព**តឹងរ៉ឹង**នៃវិធាន ៩២ស្ទួន។ វិធាន ៩២ស្ទួនមានគោលបំណង**រឹតត្បិត**ការទទួលយកភស្តុតាងប្រយោលប្រភេទពិសេសនេះ មកត្រឹមភស្តុតាងដែលស្ថិតនៅក្នុងដែនអនុវត្តនៃវិធាននេះ។ តាមសទិសភាព **វិធាន ៩២ស្ទួន គឺជាច្បាប់ចារិតពិសេស ដែលបដិប្បញ្ញត្តិទៅនឹងវិធាន ៨៩(គ) ជាច្បាប់ចារិតទូទៅដោយ ច្រានចោលនូវការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីសក្ខានុពល និងប្រតិចារឹកនៃសក្ខីកម្ម** ទោះបីជាការចោទប្រកាន់ជាទូទៅ ដែលមានដោយប្រយោលនៅក្នុងវិធាន ៨៩(គ) (ភស្តុតាងអាចទទួលយកបានតែក្នុងករណីមានភាពពាក់ព័ន្ធ ហើយភស្តុតាងមានភាពពាក់ព័ន្ធ តែប្រសិនបើវាមានតម្លៃជាក់អាចជឿទុកចិត្តបាន) នៅតែអាចអនុវត្តបាន ចំពោះវិធាន ៩២ស្ទួន ក៏ដោយ"[19]។

១៩. ភាពខុសគ្នារវាងឆន្ទានុសិទ្ធិទូលំទូលាយ ដែលផ្តល់ឱ្យដោយវិធាន ៨៩(គ) និងលក្ខខណ្ឌតឹងរ៉ឹងដែលត្រូវគោរពនៃវិធាន ៩២ស្ទួន នៅតែមានភាពច្បាស់លាស់ជានិច្ច ហើយត្រូវបានធ្វើបច្ចុប្បន្នភាពកាលពីប៉ុន្មានសប្តាហ៍មុននេះ[20]។

---

[17] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Galic* សំណុំរឿងលេខ IT-98-29-AR73.2 សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់ធ្វើឡើងអនុលោមតាមមាត្រា ៩២ ស្ទួន(គ) នៃវិធាននីតិវិធី និងភស្តុតាង ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០២ (សេចក្តីសម្រេចក្នុងរឿងក្តី *Galic*)។

[18] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា *រដ្ឋអាជ្ញា តទល់នឹង Karemera និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ICTR-98-44-T សេចក្តីសម្រេចលើសំណើសុំរបស់រដ្ឋអាជ្ញាមានចំណងជើងថា "សំណើរបស់រដ្ឋអាជ្ញាសុំឱ្យទទួលយកភស្តុតាងទាក់ទងនឹងការរំលោភសេពសន្ថវៈ និងការបៀតបៀនផ្លូវភេទ អនុលោមតាមវិធាន ៩២ស្ទួន នៃវិធាននីតិវិធី និងភស្តុតាង និងដីកាបង្គាប់ឱ្យកាត់បន្ថយបញ្ជីឈ្មោះសាក្សីរបស់រដ្ឋអាជ្ញា" ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៦ (សេចក្តីសម្រេចក្នុងរឿងក្តី *Karemera*) កថាខណ្ឌ ១០។

[19] សេចក្តីសម្រេចក្នុងរឿងក្តី *Galic* កថាខណ្ឌ ៣១ (មិនមានអក្សរដិត ក្នុងឯកសារដើម)។

[20] ឧទាហរណ៍ សូមមើល៖ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា *រដ្ឋអាជ្ញា តទល់នឹង Nzabonimana* សំណុំរឿង

បង្ហាញខ្លួនក្នុងសវនាការដើម្បីសួរដេញដោល[23]។ ចៅក្រមបានកត់ត្រាទឡ្ហីករណ៍របស់រដ្ឋអាជ្ញាពាក់ព័ន្ធនឹងរយៈពេលនៃការជំនុំជម្រះក្តី ហើយចងចាំនូវកាតព្វកិច្ចក្នុងការធានាឱ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងឆាប់រហ័ស៖ "ការទទួលយកកំណត់ហេតុស្តាប់ចម្លើយ អនុលោមតាមវិធាន ៩២ស្ទួន(ង) និងការកោះហៅសាក្សីឱ្យចូលមកបង្ហាញខ្លួនក្នុងសវនាការសួរដេញដោល អាចបម្រើឱ្យគោលដៅទាំងនេះបានប្រសើរបំផុត ធ្វើឱ្យចំណេញពេលវេលាច្រើនដែលប្រើប្រាស់សម្រាប់ការស្តាប់ចម្លើយដំបូង" [24]។

២៣. ដើម្បីគាំទ្រដល់ការទាញហេតុផលរបស់ខ្លួន សហព្រះរាជអាជ្ញាដកស្រង់ឃ្លាមួយនៃសេចក្តីប្រកាសរបស់ចៅក្រម Kwon ដែលយល់ស្របនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី។ ផ្ទុយទៅវិញ នៅពេលដាក់ឃ្លានេះនៅក្នុងបរិបទទូទៅនៃការធ្វើសក្ខីកម្ម ច្បាស់ណាស់ថាចៅក្រមរូបនេះនិយាយពីការទទួលយកសក្ខីកម្មមុនៗរបស់សាក្សី បន្ថែមពីលើសក្ខីកម្មនៅក្នុងសវនាការ គឺមិនមែនកំណត់ហេតុស្តាប់ចម្លើយ ជំនួសឱ្យសក្ខីកម្មដោយផ្ទាល់មាត់នោះទេ[25]។

២៤. ជាចុងក្រោយ សហព្រះរាជអាជ្ញាកត់សម្គាល់ថា នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី សូម្បីនៅមុនការអនុម័តវិធាន ៩២ស្ទួន នៃវិធាននីតិវិធី និងភ័ស្តុតាង អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីទទួលយកកំណត់ហេតុស្តាប់ចម្លើយជាភ័ស្តុតាង ហើយសហព្រះរាជអាជ្ញាបានដកស្រង់ឃ្លាមួយនៃសាលដីកាក្នុងរឿងក្តី *Aleksovski*[26]។ ក៏ប៉ុន្តែ ក្រោយពីអានសាលដីកានោះ ច្បាស់ណាស់ថាមុននឹងអនុម័តវិធាន ៩២ស្ទួន អង្គជំនុំជម្រះសាលាដំបូងមានភាពតឹងរ៉ឹង និងប្រយ័ត្នប្រយែងជ្រុលរួចទៅហើយ ចំពោះការទទួលយកការផ្តល់

---

[23] សេចក្តីសម្រេចក្នុងរឿងក្តី *Milosevic* កថាខណ្ឌ ២៧ និងកថាខណ្ឌ ៣០។

[24] សេចក្តីសម្រេចក្នុងរឿងក្តី *Milosevic* កថាខណ្ឌ ២៦។

[25] ជាក់ស្តែង ចៅក្រម Kwon យល់ឃើញថា "(១) នៅពេលដែលមេធាវីការពារក្តីឯកភាព (...) ឬ (២) នៅពេលម្ចាស់ចម្លើយបង្ហាញខ្លួនក្នុងនាមជាសាក្សី ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃខ្លឹមសារនៃចម្លើយរបស់ខ្លួន និងនៅពេលមានការសួរដេញដោលដោយភាគីបដិបក្ខ អង្គជំនុំជម្រះសាលាដំបូងត្រូវដាក់បញ្ចូលកំណត់ហេតុស្តាប់ចម្លើយទាំងនោះទៅក្នុងសំណុំរឿង", សេចក្តីសម្រេចក្នុងរឿងក្តី *Milosevic* សេចក្តីប្រកាសរបស់ចៅក្រម O-Gon Kwon កថាខណ្ឌ ២។

[26] សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៧ និងកំណត់សម្គាល់ជើងទំព័រលេខ ៤៦។

នីតិវិធី និងភ័ស្តុតាងរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ ចែងថា៖

"បន្ទាប់ពីស្តាប់ចម្លើយភាគីនានារួចហើយ អង្គជំនុំជម្រះសាលាដំបូងសម្រេចថាតើនឹងបង្គាប់ ឬមិនបង្គាប់ឱ្យសាក្សីចូលមកបង្ហាញខ្លួននៅក្នុងសវនាការ ដើម្បីសួរដេញដោល។ អង្គជំនុំជម្រះអាចសម្រេចថា ផលប្រយោជន៍នៃយុត្តិធម៌ និងតម្រូវការនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ និងឆាប់រហ័សទាមទារ **ជាករណីលើកលែង** ឱ្យមានការទទួលយកកំណត់ហេតុ ឬប្រតិចារឹកទាំងស្រុង ឬដោយផ្នែក ដោយមិនចាំបាច់ធ្វើការសួរដេញដោល។ អង្គជំនុំជម្រះផ្តល់សំអាងហេតុដល់សេចក្តីសម្រេចរបស់ខ្លួន (...)[30]។

២៧. លើសពីនេះទៀត យើងត្រូវកត់សម្គាល់ថា ខ្លឹមសារនៃវិធាន ១៥៥ នៃវិធាននីតិវិធី និងភ័ស្តុតាងរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ ស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងវិធាន ៩២ ស្ទួន នៃវិធាននីតិវិធី និងភ័ស្តុតាងរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា។ លើកលែងតែកត្តាមួយដែលបញ្ជាក់អំពីការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីជាភ័ស្តុតាង ត្រូវបានបន្ថែម។ គឺជាករណីដែលភ័ស្តុតាងទាំងនោះ "ត្រូវបានសាក្សីផ្តល់ នៅចំពោះមុខភាគីដែលមានលទ្ធភាពសួរ ឬសួរដេញដោលសាក្សីនោះវិញ"[31]។

២៨. ដូច្នេះ ចំពោះតុលាការពិសេសសម្រាប់ប្រទេសលីបង់ ការស្តាប់ចម្លើយសាក្សីចំពោះមុខ គឺនៅតែជាគោលការណ៍ជានិច្ច ទោះបីជាមុន ឬក្នុងពេលជំនុំជម្រះក្តីក៏ដោយ ចំណែកឯការទទួលយកកំណត់ហេតុស្តាប់ចម្លើយជំនួសឱ្យសក្ខីកម្មដោយផ្ទាល់មាត់ ដោយគ្មានការសួរដេញដោលសាក្សីត្រូវស្ថិតនៅជាករណីលើកលែង។

## III. ការអនុវត្តគោលការណ៍ខាងលើនៅចំពោះមុខ អ.វ.ត.ក

---

[30] មិនមានអក្សរផិត ក្នុងឯកសារដើម។

[31] វិធាន 155 A) i) g) នៃវិធាននីតិវិធី និងភ័ស្តុតាង របស់តុលាការពិសេសសម្រាប់ប្រទេសលីបង់។ វិធាន 155 A) i) a) ដល់ f) ដូចគ្នាទៅនឹងវិធាន ៩២ស្ទួន A) i) a) ដល់ f) នៃវិធាននីតិវិធី និងភ័ស្តុតាង របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា។

៣២. សូមអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- ច្រានចោលសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា។

**រក្សាសិទ្ធិគ្រប់យ៉ាង**
**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី ស សូវាន<br><br>មេធាវី Jacques VERGÈS | ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |